# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៥៦ សសរ**

## សេចក្តីសម្រេច

**ស្តីពី**

**ការបង្កើតគណៈកម្មការ និងអនុគណៈកម្មការរៀបចំពិធីបុណ្យសព**

**ឯកឧត្តម ហ៊ឹម ឆែម ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.**_

ត្រូវបានបង្កើតគណៈកម្មការ និងអនុគណៈកម្មការនានា ដើម្បីរៀបចំពិធីបុណ្យសពឯកឧត្តម **ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ដែលមានសមាសភាពដូចខាងក្រោម៖

**ក.គណៈកម្មការរៀបចំបុណ្យសព**

| | | |
|---|---|---|
| ១. ឯកឧត្តម | **ឈិត សុខុន** | ប្រធាន |
| ៣. ឯកឧត្តម | **ឈិន កេតនា** | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | | សមាជិក |
| ៥. រដ្ឋលេខាធិការក្រសួងការពារជាតិ | | សមាជិក |

៦. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៧. រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា សមាជិក
៨. រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
៩. រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល សមាជិក
១០.ឯកឧត្តម **ថាច់ ផែន** សមាជិក
១១.ឯកឧត្តម **សាន់ សាប់អី** សមាជិក
១២.ឯកឧត្តម **ហ៊ី ទិរៈ** សមាជិក
១៣.ឯកឧត្តម **មួន លឹមហេង** សមាជិក
១៤.ឯកឧត្តម **ឃួង ស្រេង** សមាជិក
១៥.ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** សមាជិក
១៦.ឧត្តមសេនីយ៍ទោ **អ៊ុក សារឹម** សមាជិក

គណៈកម្មការនេះ មានភារកិច្ចចាត់ចែងរៀបចំបុណ្យសពឯកឧត្តម **ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ឲ្យបានសមរម្យតាមទំនៀមទម្លាប់ ប្រពៃណី ស័ក្តិសមទៅនឹងកិត្តិយសរបស់សព។ សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ។

**ខ.អនុគណៈកម្មការពិធីសាសនានៅគេហដ្ឋាន និងពិធីដង្ហែសពទៅឈាបនដ្ឋាន**

១. ឯកឧត្តម **នរៈ រតនៈវឌ្ឍនោ** ប្រធាន
២. ឯកឧត្តម **ញាណ ភឿន** អនុប្រធានអចិន្ត្រៃយ៍
៣. ឯកឧត្តម **សេង សុមុនី** អនុប្រធាន
៤. អ្នកឧកញ៉ាកក្តីព្រះស្តេច **ហេង គឹមគុណ** អនុប្រធាន
៥. ឯកឧត្តម **សោម រតនា** សមាជិក
៦. ឯកឧត្តម **ស៊ិន សុវណ្ណនិ** សមាជិក
៧. ឯកឧត្តម **ដោក កុសល** សមាជិក
៨. ឯកឧត្តម **សាន សម្ផស្ស** សមាជិក
៩. ឯកឧត្តម **បុណ្យ ប៊ុនសារ៉ាត់** សមាជិក
១០.ឯកឧត្តម **សេង សុភី** សមាជិក
១១.ឧត្តមសេនីយ៍ត្រី **អ៊ុន សុធី** សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំកម្មវិធីបុណ្យ កន្លែងធ្វើបុណ្យ និងពិធីគោរពវិញ្ញាណក្ខន្ធនៅគេហដ្ឋាន
- រៀបចំក្រុមបដិសណ្ឋារកិច្ចនៃអង្គភាពត្រៃទ័ព
- ចាត់ចែងពិធីសាសនាពាក់ព័ន្ធព្រះសង្ឃ និងលោកអាចារ្យ
- រៀបចំព្រះមេរុ និងវេទិកានៅឈាបនដ្ឋាន
- រៀបចំវិយោគកថា
- ចាត់ចែងឈាបនកិច្ច

- ទទួលភារកិច្ចផ្សេងទៀត តាមការចាត់តាំងពីប្រធានគណៈកម្មការ។

**គ.អនុគណៈកម្មការពិធីការ បដិសណ្ឋារកិច្ច និងព័ត៌មាន**

| | | |
|---|---|---|
| ១. លោកជំទាវ | **ទូច សារ៉ុម** | ប្រធាន |
| ២. ឯកឧត្តម | **ឌ៉ាន់ ម៉ុនឡាយ** | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. ឯកឧត្តម | **ផាន់ ចន្ទតារា** | អនុប្រធាន |
| ៤. លោក | **ឈិត សុគន្ធី** | អនុប្រធាន |
| ៥. ឯកឧត្តម | **ហុង សារឿនពេញ** | សមាជិក |
| ៦. ឯកឧត្តម | **រិត ខេមរារស្មី** | សមាជិក |
| ៧. ឯកឧត្តម | **គីម ជួប** | សមាជិក |
| ៨. តំណាងអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា | | សមាជិក |
| ៩. តំណាងអគ្គនាយកដ្ឋានវិទ្យុជាតិ | | សមាជិក |
| ១០.លោក | **ឈឹម ច័ន្ទឬទ្ធី** | សមាជិក |
| ១១.លោកស្រី | **ហ៊ឹម ធីតាកែវ** | សមាជិកា |

អនុគណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតជូនដំណឹងមរណភាព
- រៀបចំពិធីការទទួលគោរពវិញ្ញាណក្ខន្ធ
- រៀបចំលិខិតស្នាមរដ្ឋបាលផ្សេងៗ
- លើកសំណើសុំមេដាយជាកិច្ចមច្ឆាមរណៈ
- រៀបចំចាត់ចែងរាល់ការផ្សព្វផ្សាយព័ត៌មានដែលមានការពាក់ព័ន្ធនឹងពិធីបុណ្យសព
- ទទួលភារកិច្ចផ្សេងទៀត តាមការចាត់តាំងពីប្រធានគណៈកម្មការ។

**ឃ.អនុគណៈកម្មការសន្តិសុខ**

| | | |
|---|---|---|
| ១. ឯកឧត្តម | **ឃួង ស្រេង** | ប្រធាន |
| ២. ឯកឧត្តមឧត្តមសេនីយ៍ឯក | **ស ថេត** | អនុប្រធាន |
| ៣. ឯកឧត្តមឧត្តមសេនីយ៍ឯក | **រ័ត្ន ស្រ៊ាង** | អនុប្រធាន |
| ៤. លោកអភិបាល នៃគណៈអភិបាលខណ្ឌច្បារអំពៅ | | សមាជិក |
| ៥. លោកអភិបាល នៃគណៈអភិបាលខណ្ឌដូនពេញ | | សមាជិក |

អនុគណៈកម្មការនេះ មានភារកិច្ចរៀបចំសណ្ដាប់ធ្នាប់ សន្តិសុខសម្រាប់កម្មវិធីបុណ្យទាំងមូល ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ។

**ង.អនុគណៈកម្មការផ្គត់ផ្គង់ និងហិរញ្ញវត្ថុ**

| | | |
|---|---|---|
| ១. ឯកឧត្តម | **សារ៉ាយ ឆុន** | ប្រធាន |
| ២. ឯកឧត្តម | **ហ៊ឹម សុចិត្រា** | អនុប្រធាន |
| ៣. ឯកឧត្តម | **រស់ ចណ្ណារី** | អនុប្រធាន |

៤. លោក **ស៊ាន សេរីវឌ្ឍី** សមាជិក

៥. លោក **សរ លីនដា** សមាជិក

៦. លោកស្រី **ម៉ាន់ ស្រីអូន** សមាជិកា

៧. លោក **ប៊ុន សម្បត្តិ** សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ចរៀបចំ និងដោះស្រាយរាល់ការចំណាយផ្សេងៗសម្រាប់កម្មវិធីបុណ្យ។

**ប្រការ២.**_

គណៈកម្មការនេះ អាចបង្កើតអនុគណៈកម្មការ និងក្រុមការងារបន្ថែមជាជំនួយការ និងប្រើប្រាស់មន្ត្រីក្រោមឱវាទតាមការចាំបាច់ ដើម្បីជានាឲ្យការរៀបចំពិធីបុណ្យប្រព្រឹត្តទៅតាមប្រពៃណីព្រះពុទ្ធសាសនាឲ្យបានល្អប្រសើរ។ គណៈកម្មការនេះ អាចប្រើប្រាស់ត្រាក្រសួងធម្មការ និងសាសនា ដើម្បីដំណើរការសកម្មភាពការងាររបស់ខ្លួន។

**ប្រការ៣.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវអនុវត្តសេចក្ដីសម្រេចនេះឲ្យមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអាទិត្យ ១១ រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

***កន្លែងទទួល***

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*

*-ដូចប្រការ ៣*

*-រាជកិច្ច*

*-ឯកសារ-កាលប្បវត្តិ*